# ការសំភាសន៍របស់អ្នកមីង ផាត វៀត

**កៈ អ្នកដែលសំភាសន៍ រឹទ្ធ សុនតានិច្ច        ខៈ អ្នកដែលត្រូវគេសំភាសន៍ ផាត វៀត**

## ជីវប្រវត្តិសង្ខេបជាលើកទី២របស់លោកពូ ឡាយ ផល្លី

អ្នកមីង ផាត វៀត មានទីលំនៅបច្ចុប្បន្ននៅស្រុកភ្នំក្រោម ខេត្តសៀមរាប។ គាត់មានបងប្អូន៤នាក់ ហើយគាត់ជាកូនទី២។ គាត់មានស្រុកកំណើតនៅកូមិផ្ការំចេក ខេត្តសៀមរាប។ អ្នកមីងកើតនៅឆ្នាំ ១៩៧៦ បច្ចុប្បន្នមានកូនស្រី២នាក់។

កៈ អូខេ ចឹងជាដំបូងខ្ញុំសូមអរគុណអ្នកមីងដែលបានផ្តល់ដូចជាពេលវេលាសម្រាប់ខ្ញុំ សំភាស៍ទៅកាន់អ្នកមីងអំពីដូចជាជីវប្រវត្តិផ្ទាល់របស់អ្នកមីងចឹងហារ!

ខៈ ចាស

កៈ ហើយជីវប្រវត្តិ ហើយការសំភាសន៍មួយនេះគឺបានបង្កើតឡើងដោយសកលវិទ្យាល័យមួយដែលគេហៅកាត់ថា BYU ដែលនៅសហរដ្ឋអាមេរិចហើយគោលបំណងរបស់សកលវិទ្យាល័យនេះគឺដើម្បីថែរក្សាជីវប្រវត្តជីដូនរបស់អ្នកមីងសម្រាប់ទុកអោយកូនៗរបស់អ្នកមីងជំនាន់ក្រោយពួកគាត់អាចដឹងអំពីអនុស្សាវរីយ៍អ្នកមីងផ្សេងៗចឹង

ខៈ ចាស

កៈ ហើ ចាស ហើយចឹងអ្នកមីងតើអ្នកមីងឈ្មោះពេញរបស់អ្នកមីងអ្វីដែលអ្នកមីង?

ខៈ ឈ្មោះពេញហារ?

កៈ ចាស

ខៈ ឈ្មោះពេញឈ្មោះហ្នឹងឯង ឈ្មោះនៃកតាំងពីកំណើតមក

កៈ ចាស ឈ្មោះអីគេដែលមីង អាចហៅម្តងទៀត

ខ៖ ឈ្មោះនែក ឈ្មោះ ផាត វៀត

ក៖ ផាត វៀត ចាស

ខ៖ ចាស

ក៖ អ្នកមីងឆ្នាំនេះអ្នកមីងអីអ្នកមីងអាយុប៉ុន្មានហើយ?

ខ៖ អាយុ ៩១ហើយ

ក៖ ៩១ឆ្នាំ ចាសចុះអីសម្រាប់អ្នកមីងអ្នកមីងវៀតឈ្មោះហៅក្រៅមានដែលទេមីង?

ខ៖ ឈ្មោះហៅក្រៅហារ?

ក៖ ចាសដូចជាគេហៅលេងនៅផ្ទះ…

ខ៖ មានហៅលេងមានមួយទៀតហារ

ក៖ គេហៅអីគេដែលមីង

ខ៖ គេហៅគេតែងហៅឈ្មោះថាមីខ្ចឹង

ក៖ អឺង

ខ៖ អឺង

ក៖ អូ ឈ្មោះដូចចិត្ត ហិហិហិ ចាសអ្នកមីងវៀត ហៅឈ្មោះហៅក្រៅហៅអ្នកមីងអឺង

ខ៖ គេតែងហៅលេងហៅអីហ្នឹងណា

ក៖ ចាសៗ ចុះក្នុងភូមិគេហៅចឹងដែរមែនទេអ្នកមីង?

ខ៖ ហៅចេះដែលៗជូនកាលឈ្មោះ២ហ្នឹងភូមិហ្នឹងគេហៅទាំង២ហ្នឹងឯង

ក៖ ចាស អូខេ ហើយអ្នកមីងកើតនៅក្នុងឆ្នាំណាអ្នកមីង? អ្នកមីងចាំទេ?

ខ៖ អឺម អត់បានចាំផងដូចថាវាយូរហើយហារ

ក៖ ចាស

ខ៖ គិតមើលទៅ៥០ឆ្នាំជាងទៅហើយ

ក៖ អូខេ ចឹងអ្នកមីងកើតនៅក្នុងឆ្នាំប៉ុន្មានដែលមីង?

ខ៖ អឺប៉ុន្មានមិញថានុះ

ក៖ ១៩៧៦

ខ៖ អឺ ១៩៧៦

ក៖ ចាស អូខេ ហើយសម្រាប់ខ្ញុំខ្មែររបស់យើងឆ្នាំមួយណាដែរអ្នកមីង?

ខ៖ ឆ្នាំខ្មែរ?

ក៖ ចាស ដូចជាជូត ឆ្លូវ អី

ខ៖ ឆ្នាំខ្មែរ ខែផល្គុន

ក៖ ខែ ផល្គុន

ខ៖ ខែ ផល្គុន ថ្ងៃសៅរ៍

ក៖ ចាសចំថ្ងៃ

ខ៖ អូ ច្រលំខុសហើយហើយម្តងទៀត ថ្ងៃពុធ

ក៖ ថ្ងៃពុធ ខែផល្គុន

ខ៖ អឺ

ក៖ ហើយឆ្នាំ ឆ្នាំណាដែលមីង?

ខ៖ ឆ្នាំ ឆ្នាំម្សាញ់

ក៖ ឆ្នាំម្សាញ់

ខ៖ ឆ្នាំខ្មែរយើងហារ

ក៖ ចាស អូខេ ហើយចឹងអ្នកមីងសម្រាប់ទីកន្លែងកំណើតរបស់អ្នកមីងនៅណាដែលអ្នកមីង

ខ៖ នៅអីហួសដំដែកយើងទៀតហារ

ក៖ ហួសភូមិដំដែក

ខ៖ នៅភូមិផ្ការំចេក ឃុំត្រចេក ខេត្តសៀមរាបយើងនេះ

ក៖ ចាស ប៉ុន្តែទីលំនៅបច្ចុប្បន្ន?

ខ៖ បច្ចុប្បន្នស្នាក់នៅភ្នំក្រោម

ក៖ ភ្នំក្រោម ជាអីជាទីកន្លែងកំណើររបស់ស្វាមីរបស់អ្នកមីងឬក៏ម៉េចដែរអ្នកមីង?

ខ៖ ស្វាមីនៅ នៅភូមិកំណើតនុះ

ក៖ អ

ខ៖ ភូមិកំណើរនៅអន្លង់២

ក៖ នៅអន្លង់២

ខ៖ ហ្នឹងហើយ

ក៖ អូ ឆ្ងាយហារ

ខ៖ អន្លង់២ តានេះយើងនែក ជិតទេ

ក៖ អៗ មែនហួសអី ចាសៗ

ខ៖ ជិតនេះទេ

ក៖ អន្លង់២ ចឹងអីអ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែរមីង?

ខ៖ មានបងប្អូន៤នាក់

កៈ ៩នាក់ ហើយអ្នកមីងជាកូនទីប៉ុន្មានដែរ?

ខៈ ទី២

កៈ ទី២ ហិហិហិ អ្នកមីងអាចជម្រាប

ខៈ អឹម និយាយនេះខុសទៀត ហិហិហិ

កៈ ហិហិហិ

ខៈ ចូលទី៣ហើយ

កៈ ទី៣ ចាស

ខៈ ទី៣ ហើយ

កៈ អ ហើយអ្នកមីងអាចជម្រាបឈ្មោះរបស់បងប្អូនអ្នកមីងបានហេ?

ខៈ បងហារ

កៈ ចាស

ខៈ មានត្រកូលតែមួយហ្នឹងឯងឈ្មោះអឹបងជាងគេឈ្មោះអឹបងទី១ឈ្មោះ ផាត ភាព

កៈ ចាស

ខៈ ទី២ឈ្មោះអឹ ផាត សុវៃន ប្អូនទីបញ្ចប់នុះឈ្មោះ ផាត ផល

កៈ ផាត ផល ចឹងអ្នកមីងជាកូនទី៣ ហើយប្អូនពៅរបស់អ្នកមីងគាត់ឈ្មោះ ផាត ផល

ខៈ ចាស

កៈ កូនទី៣ របស់អ្នកមីងគាត់អាយុប៉ុន្មានដែរអ្នកមីង?

ខៈ ទី៣ ហារ? កូនហារ?

កៈ អូ ប្អូនៗ ច្រលំ

ខ៖ ប្អូនទី៣ អាយុ៣០ជាង

ក៖ ៣០ជាងហើយ

ខ៖ ចាស

ក៖ សព្វថ្ងៃបងប្អូនអ្នកមីងរស់នៅជុំគ្នាឬក៏ផ្សេងៗ

ខ៖ បែកគ្នាអស់ហើយ បានប្តីប្រពន្ធទៅបែកគ្នារកស៊ីអស់

ក៖ អ ចាស

ខ៖ តាមប្តីប្រពន្ធរៀងៗខ្លួន

ក៖ តាមប្តីប្រពន្ធ អូខេ ហើយអឺអ្នកមីងអឺនៅចងចាំសាច់រឿងអ្វីខ្លះអីពួកគាត់នៅពីក្មេងៗដែរទេមីង?

ខ៖ ចង់និយាយអីគេ?

ក៖ ចាស

ខ៖ សួរមកចាស់ កាលសង្គ្រាមកើតទាន់សម័យពល ពត ចូលហើយហារ

ក៖ ចាស

ខ៖ ស្រុកសង្គ្រាមសម័យពត ពត ចូលយួនចូលហើយនុះ

ក៖ ចាសៗ

ខ៖ កើតទាន់ធំដឹងក្តីហើយ កាលយួនចូលមកហើយជំនាន់អាពតចូលមកឡើងខៀវពេញស្រុកហារ កាលនុះនៅរៀនថ្នាក់តិចទេប៉ុន្តែ ដូចភូមិយើងអត់មានសាលារៀនហារ

ក៖ ចាស

ខ៖ ត្រឹមថ្នាក់ទី៥អត់មានទេនៅភូមិយើង គេយ៉ាប់ពេកហ្នឹងឯង

ក៖ ចាស

ខ៖ ជិះមករៀនឯនេះសាលារៀនថ្មល់ជ័យ ដល់តែទៅរៀនមកវិញចូលភូមិអត់រួច ចូលភូមិអ្នករួចនៅដេកភូមិតាមគេថ្មល់ជ័យ អ្នកមានបាននៅជាមួយយាយអត់មានបាននៅជាមួយម៉ែនៅជាមួយយាយ ទៅដល់ផ្ទះវិញយាយខឹងអើយខឹង

ក៖ ហិហិហិ

ខ៖ ខឹងនែកៗមករៀនហ្នឹងគេ ទៅគាត់ខឹង គាត់អោយឈប់ៗរៀនរហូត

ក៖ ចាស

ខ៖ បានត្រឹមថ្នាក់ទី៥ឈប់រហូត បើម៉ែឪបែកបាក់អស់ហើយមានពីណាគ្រប់គ្រងយើងទៀត

ក៖ ចុះពេលដែលអ្នកមីងកំឡុងពេលដែលអ្នកមីងនៅក្មេង ការទទួលខុសត្រូវអ្នកមីងចំពោះក្រុមគ្រួសារអ្នកមីងមានច្រើនអត់

ខ៖ ក្រុមគ្រួសារ...ក្រុមគ្រួសាររឿងប្ដីប្រពន្ធហារ/

ក៖ អត់ទេ បងប្អូនរបស់អ្នកមីង

ខ៖ រឿងបងប្អូនអត់អីទេ ប៉ុន្ដែពេលដែលសួរខ្ញុំទឹកភ្នែកឈូ

ក៖ ចាស ហិហិហិ

ខ៖ នែកវាកំសត់កាលនៅពីតូច ចុះនៅជាមួយយាយហារ

ក៖ ចាស

ខ៖ យាយគាត់ធ្វើបាប ដល់បានធំដឹងក្ដីទៅបានចេះស្គាល់ផ្លូវដើររកស៊ីកើត ហើយឯងបានរួចខ្លួន

ក៖ អ្នកមីងរស់នៅជាមួយលោកយាយប៉ុន្មានឆ្នាំដែរអ្នកមីង?

ខ៖ នៅតាំងពីតូចតាំងពីអាយុប្រហែលតាំងពី១០ហ្វ

ក៖ ចាស ចឹងចាប់ផ្ដើមរស់នៅខ្លួនឯង

ខ៖ ចុះម្ដាយឪពុកគាត់ស្លាប់ទៅក៏នៅជាមួយយាយតាំងពីអាយុ១០ហ្ង ពីហ្នឹងរបស់ដល់តែមានគ្រួសារ មានគ្រួសារទៅបានបែកពីគាត់ ចេះតែទ្រាំទៅណាគាត់ធ្វើបាបយ៉ាងម៉េចចេះតែទ្រាំទៅណា

ក៖ ចាស

ខ៖ ហ្នឹងឯងនៅជាមួយគាត់ដល់មានគ្រួសារទៅបានចេញពីគាត់បែកពីគាត់រហូត

ក៖ អឹមហឺ អ្នកមីងនៅក្មេងចូលចិត្តធ្វើអ្វីជាងគេដែរអ្នកមីង?

ខ៖ កាលនៅតូចហារ?

ក៖ ចាស

ខ៖ អឺកាលនៅពីក្មេងមិនដឹងធ្វើអី នែកទៅដើរលេងហ្នឹងគេចេះទៅ មិនដឹងធ្វើអីដើរទៅរើសអុសទៅរែកទឹកអីទៅណា

ក៖ ចាស

ខ៖ ណាស់នៅពីក្មេងៗហ្នឹងឯង ទៅកាលមកវិញយាយគាត់ខឹង មិនបានដើរលេងដើរអីទេ បានចេញដើរទៅរែកទឹក ទៅៗស្រែទៅអីទៅណា

ក៖ ចាស

ខ៖ បិតភ្លឺស្រែ ទៅស្ទូងទៅអីហ្នឹងឯង

ក៖ ហើអឺពេលដែលអ្នកមីងនៅក្មេងតើដែលមានអារម្មណ៍ថាខ្លួនឯងធំឡើងចង់ធ្វើអ្វីដែរទេ? គោលបំណងប្រាថ្នារបស់អ្នកកាលនៅពីក្មេងហារ?

ខ៖ បំណងប្រាថ្នាចង់ធ្វើដែរតែទៅវាមិនរួច

ក៖ ហិហិហិ មីងចង់ធ្វើអ្វីដែលអាចបង្កើបបន្តិចបានហេ?

ខ៖ ចង់ធ្វើអ្នកគ្រូអីដែរតែរៀនមិនបានចប់ហ្នឹងឯង

ក៖ ចាស

ខ៖ អត់ទៅរួចព្រោះអត់មានអ្នកគ្រប់គ្រង

ក៖ ចាស ចង់ធ្វើជាអ្នកគ្រូបង្រៀន

ខ៖ ហ្នឹងឯង

ក៖ ឡូយអ្នកមីង ហិហិហិ អូខេ ឥឡូវខ្ញុំបង្វែរសំនួរមកសួរខាងឪពុកម្ដាយអ្នកមីងដែរ ចឹងអ្នកមីងម្ដាយរបស់អ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ម៉ែគាត់ឈ្មោះ នាមត្រកូលគាត់អីទេ អត់ស្គាល់

ក៖ ចុះអ្នកមីងចាំឈ្មោះរបស់គាត់ហេ?

ខ៖ ស្គាល់ឈ្មោះ ឈ្មោះគាត់ស្គាល់ច្បាស់តើ

ក៖ ចាស

ខ៖ ឈ្មោះ រី

ក៖ ឈ្មោះ រី

ខ៖ ចាស

ក៖ ហើលោកឪពុកមានឈ្មោះអ្វីដែរមីង?

ខ៖ លោកឪពុកឈ្មោះ ផាត ហ្នឹងឯង ឈ្មោះ សាយ ផាត

ក៖ សាយ ផាត ចឹងអ្នកម្ដាយឈ្មោះ រី លោកឪពុកឈ្មោះ សាយ ផាត ចាសហើយពួកគាត់ឥឡូវអាយុប៉ុន្មានហើយមីង?

ខ៖ អាយុហេ ចូលអាយុ៥០ហើយ តែលោកពុកស្លាប់តាំងពីនៅតូចម្ល៉េះ

ក៖ អូ

ខ៖ ស្លាប់តាំងពីកើតពួកយើងអីបានមក គាត់ក៏ឈឺស្លាប់ទៅបានតែ៤នាក់ហ្នឹងឯង

កៈ អឺហឺ ចាស ចឹងពេលដែលពួកអ្នកមីងកើតមកគាត់ក៏បានទទួលអនិច្ចាកម្មទៅ ប៉ុន្តែអ្នកម្ដាយនៅសព្វថ្ងៃ?

ខៈ នៅៗ រស់ដែលបែកតាំងពីតូច ថាបែកតាំងពីតូចសម័យនុះហូគេចល័តទៅ

កៈ តែសព្វថ្ងៃនៅតែអត់បានជួបគាត់ដដែរ?

ខៈ បានជួបតែដូចថានៅឆ្ងាយមែនទែនទៅណា នៅព្រវិហារហូរម្ដាយ

កៈ អូ ចាស ហើអ្នកមីងមានអនុស្សាវរីយ៍ជាមួយឪពុកច្រើនទេ ឪពុករបស់មីងហារ?

ខៈ អត់ អត់ទាន់ដឹងក្ដីអត់មានសោះ

កៈ អត់មានសោះតែម្ដង តែអ្នកម្ដាយប្រហែលជាមានខ្លះៗ ហើមីងដឹងថាពួកគាត់ទាំង២កើតនៅក្នុងឆ្នាំណាដែរទេមីង?

ខៈ អត់ដឹងថាគាត់កើតនៅឆ្នាំណាដែរ បើយើងនៅតូចដែរហ្នឹង

កៈ ចាសៗ អត់អីទេអ្នកមីង ហើពួកគាត់ៗស្រុកកំណើតរបស់ពួកគាត់នៅណាដែរមីង?

ខៈ អឺនៅ ស្វាយលើ

កៈ នៅស្រុក ស្វាយលើ ?

ខៈ ស្រុកស្វាយលើ

កៈ ទាំង២នាក់មែនទេអ្នកមីង?

ខៈ ម្ដាយនៅស្រុកស្វាយលើ ឪពុកនៅភូមិជាមួយខ្ញុំនេះណា

កៈ អូ ចាស ចុះអឺសម្រាប់អ្នកម្ដាយរបស់មីងពេលដែលគាត់នៅជាមួយអ្នកមីងគាត់ធ្វើអ្វីដើម្បីចិញ្ចឹមជីវិតដែរអ្នកមីង?

ខៈ កាលនៅជាមួយគាត់ដើរទិញអីលត កន្លែងណាអីតិតក់ទៅណាចិញ្ចឹមកូន

កៈ ចាសដើររែកលត ហើយអ្នកមីងចេះធ្វើលតពីគាត់ដែរទេ?

ខ៖ អត់ចេះផង

ក៖ អត់ចេះទេ អូខេ ចុះមីងម្ដាយរបស់មីងគាត់ជាមនុស្សយ៉ាងម៉េចដែរគាត់កាចគាត់ស្លូត?

ខ៖ គាត់ស្លូតគាត់នៅហ្នឹង គាត់ចង់នៅគ្រប់គ្រងកូនដែរតែដល់ពេលលោកឪពុកស្លាប់ទៅគាត់នៅជាមួយម្ដាយក្មេកវាយ៉ាប់ពេក បានគាត់ទៅចោលកូនហារ

ក៖ អ

ខ៖ ម្ដាយក្មេកកាចណាស់ យាយនុះកាចពេក គាត់សុខចិត្តចោលកូន គាត់ចង់យកកូនទៅប៉ុនយាយអត់អោយយកទៅ គាត់ក៏ទៅតែឯងទៅក៏បែកកូន

ក៖ ចឹងលោកយាយដែលអ្នកមីងនៅជាមួយគឺជាលោកយាយខាងប៉ា ខាងឪពុករបស់អ្នកមីង?

ខ៖ ចាស

ក៖ អ ចាសៗ ដែលជាម្ដាយក្មេក ហើយមីងចាំសាច់រឿងអំពីម្ដាយឪពុករបស់មីងទេ?

ខ៖ អត់ទាន់ដឹងក្ដីសោះ អត់ដឹង

ក៖ ហិហិហិ ហីពួកគាត់ធ្លាប់ប្រាប់ពីជីវិតពួកគាត់កាលគាត់នៅក្មេងៗហេ?

ខ៖ អត់ ដឹងតែត្រឹមថា លឺអ្នកស្រុកនិយាយប្រាប់ថាយាយហ្នឹងណា យាយម៉ែក្មេកហ្នឹងណាធ្វើបាបគាត់

ក៖ ចាស ហីដូចជាបង្វែរមកខាងជីដូនជីតារបស់អ្នកមីងវិញតើមីងចាំឈ្មោះរបស់ជីដូនជីតារបស់មីងដែរទេ តាយាយរបស់មីងហារ?

ខ៖ តាយាយស្គាល់ យាយបង្កើតឈ្មោះ បេង រ៉ាម

ក៖ បេង រ៉ាម

ខ៖ យាយៗខាងណាទៀត យាយខាងពុកហារ យាយខាងម៉ែហារ?

ក៖ ចាសទៅ២ យាយរបស់អ្នកមីងទាំង៤ លោកយាយនិងលោកតា

ខ៖ អ ចាំបានតែមួយប៉ុណ្ណោះឯង

ក៖ អូ ចាំបានតែម្នាក់ហ្នឹងឯង អ៊ីលោកយាយរបស់អ្នកមីងគាត់នៅណាដែរអ្នកមីង?

ខ៖ នៅឆ្ងាយ នៅក្បែរយើងនេះណា

ក៖ អូចាស

ខ៖ ខ្វាក្ប

ក៖ ហើពួកគាត់ដែលនិយាយរឿងប្រាប់អ្នកមីងដែរទេកាលពីគាត់នៅក្មេងៗអីចឹងហារ

ខ៖ គាត់និយាយតើរឿងកប្លែងអី ដូចជាកំណាព្យអី

ក៖ ចាស ហ្នឹងហើយ អូខេ ហើសម្រាប់អ៊ីអ្នកមីងក្រុមគ្រួសារអ្នកមីងរស់នៅខេត្តសៀមរាបនេះដ
ដែររយៈពេលយូរហើយមែនទេអ្នកមីង?

ខ៖ នៅខេត្តសៀមរាបហ្នឹង នៅយូរហើយតាំងពីកើតមក

ក៖ ដែលមានដូចជាផ្លាស់ប្តូរទៅខេត្តផ្សេងៗអីចឹងហារ

ខ៖ អត់ អត់ដែលមានទេ

ក៖ ចឹងមានតែសៀមរាបរបស់យើង

ខ៖ ហ្នឹងឯង សៀមរាបយើងហ្នឹងឯង

ក៖ ចុះមីងមានសាច់ញាតិដែលរស់នៅក្រៅប្រទេសកម្ពុជាយើងហោ?

ខ៖ អត់មានសោះ

ក៖ អត់មានទេ

ខ៖ អត់មានទេ

ក៖ ចាស ហើសម្រាប់អាពាពិពាហ៍របស់អ្នកមីងវិញសាម៉ីរបស់មីងឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឈ្មោះ ញឹម កុ

ក៖ ញឹម កុ គាត់មានឈ្មោះហៅក្រៅដែរទេមីង?

ខ៖ អត់ គាត់មានឈ្មោះតែមួយប៉ុណ្ណឹងឯង

ក៖ ចាស ហើអ្នកមីងរៀបអាពាពិពាហ៍នៅឆ្នាំណាមីងចាំអត់?

ខ៖ អូឆ្នាំតាំងពីអាយុ២៥

ក៖ អាយុ២៥

ខ៖ យូរហើយ

ក៖ មកដល់ឥឡូវមីង៨២ហើយចឹងច្រើនហារ

ខ៖ ចាស ហិហិហិ

ក៖ ១៥ ១៦ឆ្នាំជាង

ខ៖ ច្រើនហើយ

ក៖ ចាស ហើយអាពាពិពាហ៍របស់អ្នកមីងជាការរៀបចំដោយឪពុកម្តាយរបស់អ្នកមីងឬក៏ជាការស្រឡាញ់របស់អ្នកមីងទាំង២

ខ៖ ទេអត់ទេដើរផ្លូវកាត់ទេ

ក៖ ចឹងជាការសម្រេចចិត្តរបស់អ្នកមីងនិងលោកពូតែ២នាក់

ខ៖ ចាស

ក៖ ចាសចុះអ្នកមីងរៀបអាពាពិពាហ៍នៅពេលណាដែរមីង អូសូមទោសដូចជាថ្លៃជំនូនហារ ថ្លៃជំនូនទៅ

ខ៖ អត់ដែរមានទេពីថ្ងៃរៀបកាលដែលបាននុះឯង

កៈ ហើយអ្នកមីង ខ្ញុំចង់អោយអ្នកមីងប្រាប់ពីដំណើររឿងដូចជាស្នេហ៍របស់អ្នកមីងនៅពេលដែលជួបលោកពូយ៉ាងម៉េចខ្លះអីយ៉ាងម៉េចខ្លះបែបហ្នឹងហារ ហិហិហិ រំលឹកអនុស្សាវរីយ៍ឡើងវិញ

ខៈ ជួបឃើញទៅក៏ស្រឡាញ់ ស្រឡាញ់ទៅក៏មិនបានជាប្រគាប់ប្រាប់គេអោយមកដណ្ដឹងមកអីហា

កៈ ចាស

ខៈ គឺត្រូវគ្នាក៏តាមគ្នាទៅបណ្ដោយ

កៈ ហើយអ្នកមីងនៅពេលដែលលោកពូអត់ទាន់ជួបអ្នកមីងតើលោកពូពេលនុះលោកពូគាត់ធ្វើអីដែរ?

ខៈ អឺអត់មានអី នៅស៊ីឈ្នួលគេដែរ

កៈ ចាស ចុះអ្នកមីងធ្វើការអីដែរ

ខៈ អត់មានអីធ្វើការដែរដើរស៊ីឈ្នួលគេដូចគ្នាជួបគ្នា អត់មានមុនរបបពិតប្រាកដខ្លួនឯង

កៈ ហើពេលដែលអ្នកមីងជួបលោកពូដំបូងអ្នកមីងគិតថាគាត់ជាមនុស្សយ៉ាងម៉េចដែរ?

ខៈ អឺកាលយើងស្រឡាញ់ថាល្អហារ

កៈ ចាស

ខៈ ទៅគាត់មានសំងំអី ដល់យូរៗវាចេះតែទុកចិត្តមិនបានក៏លែងចោលទៅ

កៈ សព្វថ្ងៃអ្នកមីងរស់នៅតែជាមួយកូនទេមែនទេ?

ខៈ អឺ មានៗគ្រួសារមួយទៀត

កៈ អូខេ

ខៈ សព្វថ្ងៃមានគ្រួសារដែរ

កៈ ចាស ចុះសម្រាប់គ្រួសាររបស់អ្នកមីងក្រោយតើគាត់ជាមនុស្សយ៉ាងម៉េចដែឬ

ខៈ គាត់មនុស្សមិនល្អទេ

កៈ គាត់មានឈ្មោះអីដែរអ្នកមីង?

ខៈ គាត់ហារ?

កៈ ចាសស្វាមីរបស់អ្នកមីង

ខៈ គាត់ឈ្មោះញឹម កុ ហ្នឹងឯង

កៈ អ ចឹងគ្រួសារទី២របស់អ្នកមីងឈ្មោះញឹម កុ

ខៈ ទី៣ហ្នឹងឯង

កៈ គាត់ឈ្មោះអ្វីដែលអ្នកមីង?

ខៈ គាត់ឈ្មោះនេះហ្នឹងហារ

កៈ អអូ អូខេ ចឹងសម្រាប់អ្នកមីងអ្នកមីងអាចសរសេរភាសាខ្មែរ ឬក៏អានភាសាខ្មែរអីបានដែរទេអ្នកមីង?

ខៈ ដាច់តិចៗ

កៈ ចាស ដូចជាអានមើលយល់ខ្លះៗមែនទេ

ខៈ មើលបានតិចៗឈប់រៀនយូរដែរ

កៈ ចុះមីងឈប់រៀនថ្នាក់ទី៩?

ខៈ ឈប់រៀនថ្នាក់ទី៩ ជំនាន់នុះហារ

កៈ ចាស ចុះអឺអ្នកមីងរៀននៅសាលាឬក៏យ៉ាងម៉េចដែរអ្នកមីង?

ខៈ នៅរៀនសាលា

កៈ ពេលហ្នឹងមធ្យោបាយក្នុងការធ្វើដំណើរទៅសាលាតើធ្វើអ្វីដែលអ្នកមីង?

ខៈ ធ្វើអ្វីជិះកង់១ហ្នឹង

កៈ អូ ជិះកង់ អូកាលហ្នឹងមានកង់ជិះល្អអ្នកមីង

ខៈ ហិហិហិ កង់កញ្ចាស់មួយឡើងអត់ឈ្នាន់ទៀតផង ចេះតែទៅហ្នឹងគេដែរ

កៈ ចាស ចេះតែទៅហ្នឹងគេដែរ អូខេ ចុះក្រៅពីភាសាខ្មែរមីងចេះភាសាអីផ្សេងហេ?

ខៈ អត់ចេះ

កៈ អត់ចេះ

ខៈ អត់ចេះអីផង ជំនាន់ចាស់អត់បានរៀនអី

កៈ អូខេ អ្នកមីងសាលាដែលអ្នកមីងរៀនហ្នឹងគេមានដាក់ឈ្មោះអីអត់ទេ?

ខៈ ដាក់ឈ្មោះ ដាក់ឈ្មោះនាមត្រកូលរៀនហារ?

កៈ អត់ទេ សាលាបឋមសិក្សាហ្នឹងមានឈ្មោះហេ

ខៈ មានឈ្មោះសាលាបឋមសិក្សាថ្នល់ចេកយើងហ្នឹងឯង

កៈ តែសព្វថ្ងៃគេអភិវឌ្ឍន៍វាច្រើនជាងមុន

ខៈ ដឹងស្អីទេកាលហ្នឹង ១៣ ១៤

កៈ ចុះពេលដែលអ្នកមីងរៀនសាលាសភាពសាលាយ៉ាងម៉េចដែរអ្នកមីង?

ខៈ សាលាអឺ

កៈ ជាលក្ខណៈថ្ម ឬក៏ប្រក់អីចឹង?

ខៈ កាលនុះធ្វើនៅឈើទេ

កៈ ធ្វើនៅឈើនៅឡើយ

ខ៖ សព្វថ្ងៃរុះចោលអស់ហើយ គេធ្វើថ្មីទាំងអស់

ក៖ គេធ្វើថ្មី គេអភិវឌ្ឍន៍ឡើងវិញ ហើយពីផ្ទះទៅសាលាអ្នកមីងឆ្ងាយហេអ្នកមីង?

ខ៖ អូឆ្ងាយហារ ជិះកង់ម៉ាព្រឹកដែរ

ក៖ ហើពេលដែលអ្នកមីងនៅសាលារៀនអ្នកមីងមានមិត្តភក្រ្តជិតស្និតដែលធំធាត់មកជាមួយគ្នារហូតដល់បច្ចុប្បន្នដែលទេ?

ខ៖ មានតែកាលនៅរៀនផ្ទះជិតគ្នា

ក៖ ចាស

ខ៖ ផ្ទះជិតគ្នារាប់អានគ្នាទៅណា

ក៖ ចាសហើយចឹងអ្នកមីងចាំសាច់រឿងអីជាមួយពួកគាត់ដែរទេ?

ខ៖ អត់សូវមានរឿងអីផងទៅក៏ទៅមកក៏មក

ក៖ ចាស ហើអ្នកមីងចេះធ្វើដូចជាស្រែចំការអីចេះធ្វើដែរទេអ្នកមីង?

ខ៖ ធ្វើតើ

ក៖ ធ្វើស្រែ?

ខ៖ នៅកាលនុះធ្វើតើធ្វើចំការអី

ក៖ ចាស ចុះចំពោះជំនាញរបស់អ្នកមីងសម្រាប់បច្ចុប្បន្នអ្នកមីងចេះធ្វើអ្វីជាងគេដែរ?

ខ៖ បច្ចុប្បន្ន សព្វថ្ងៃនេះហារ?

ក៖ ចាស

ខ៖ សព្វថ្ងៃនេះធ្វើអីទៀតទេ

ក៖ លក្ខណៈថាមីងចេះដូចជាត្បាញកន្ទេល ដៀល កន្រ្ទែង ឬក៏ធ្វើអីផ្សេងៗកូរស្ករអីចឹងហារ

ខ៖ នៃកបើកន្ទេលចេះត្បាញ កាលនៅភូមិនុះត្បាញដែរតើ

ក៖ មីងចេះធ្វើ?

ខ៖ ចេះធ្វើដែរ

ក៖ ហើយមុខជំនាញហ្នឹងមីងស្រឡាញ់ទេ? អើយក្នុងរយៈពេល៨២ឆ្នាំនេះតើអ្នកមីងបានធ្វើការងារធ្វើខ្លះក្រៅពីការធ្វើស្រែចំការ ត្បាញកន្ទេល

ខ៖ បានធ្វើតើ នៅនេះកាប់ដី កាប់ដីផ្កា

ក៖ កាប់ដីដាំផ្កា?

ខ៖ អឺដាំដើមផ្កាអោយគេ

ក៖ ចុះអឺដូចជាការងារធ្វើនៅតាមក្រុងតាមខេត្តអីមីងដែលចូលធ្វើទេ?

ខ៖ ចូលធ្វើតាមកាលនៅពីក្មេងហារ ចូលធ្វើរត់តុរត់អីហ្នឹងនៅកន្លែងគុយទាវបាយ

ក៖ ចាសតែពេលហ្នឹងអ្នកមីងនៅក្មេងមែនទេអ្នកមីង?

ខ៖ អឺកាលនៅក្មេង ហិហិហិ

ក៖ ហិហិហិ ចាស ហើដូចជាចំណង់ចំណូលចិត្តរបស់អ្នកមីងវិញតើអ្នកមីងចូលចិត្តអ្វីដែរ?

ខ៖ ចំណង់ចំណូលចិត្តហារ?

ក៖ ចាស ដូចជាម្ហូប ដូចជាល្បែងកំសាន្ត ឬក៏ពេលទំនេរអ្នកមីងចូលចិត្តធ្វើអីចឹងហារ?

ខ៖ ពេលទំនេរចង់ទៅធ្វើការងារហ្នឹងណាតែមិនដឹងថាទៅធ្វើអីកើត ហិហិហិ

ក៖ ចាស ហើសម្រាប់បទចម្រៀងវិញមីងចូលចិត្តបទចម្រៀងអ្វីដែរ?

ខ៖ បទចម្រៀង?

ក៖ ចាស ចម្រៀងអីក៏ដោយដែលអ្នកមីងស្រឡាញ់ហារ ហិហិហិ

ខ៖ អូនឹកឃើញហើយគេហៅទៅផឹកស៊ីអីស្រវឹកតិចតួចអីច្រៀងលេងទៅណា អត់សូវចេះដែរហ្នឹង

ក៖ ចាស ហើយខ្ញុំចង់សួរដូចជាចំពោះក្រុមគ្រួសាររបស់អ្នកមីង ក្នុងក្រុមគ្រួសារមីងមានអ្នកណាចេះលេងឧបករណ៍ភ្លេងខ្មែរ ឬក៏សម័យដែរទេអ្នកមីង? កូនៗរបស់មីង ស្វាមីរបស់មីងអីចឹងហារ

ខ៖ អត់ អត់ទាំងអស់

ក៖ អត់មានអ្នកណាចេះទេ

ខ៖ អត់មានអ្នកចេះទេ

ក៖ ចាស ហើអ្នកមីងមានកូនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ កូនហារ

ក៖ ចាស កូនរបស់អ្នកមីងហារ

ខ៖ កូនខ្ញុំមានតែ២នាក់ហ្នឹងឯង

ក៖ ២នាក់ទេ មីងអាចរៀបរាប់ឈ្មោះគាត់បានទេ?

ខ៖ ឈ្មោះ១ ឈ្មោះស្រី មុំ

ក៖ ស្រីមុំ ចាសឈ្មោះនៅសាលាគាត់ឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះអឺ ឈ្មោះនៅសាលារៀនគេដាក់ឈ្មោះអឺនាមត្រកូល រ៉ុន សុរីន

ក៖ រ៉ុន សុរីន ចាសហើគាត់អាយុប៉ុន្មានហើយអ្នកមីង?

ខ៖ អាយុ១៤ ឆ្នាំហើយ

ក៖ ហើយគាត់រៀនថ្នាក់ទីប៉ុន្មានហើយអ្នកមីង?

ខ៖ រៀនបានដល់ថ្នាក់ទី៥ទេដល់ម៉ែក្រពេកនាំមករកស៊ីទៅ

កៈ ចាស

ខៈ ឈប់រហូតទៅ

កៈ ចុះកូនទី២របស់មីង

ខៈ អាយុ៦ឆ្នាំ គាត់និយាយតែនៅរស់៦ឆ្នាំ

កៈ អ ចឹងគាត់ម៉េចដែរមីង?

ខៈ នៅកូនតែ២ហ្នឹងឯងអាយុ១៤ឆ្នាំ និង៦ឆ្នាំហ្នឹងឯង

កៈ អ ចាស ចឹងកូនអ្នកមីងដែលបង្កើតមកមានប៉ុន្មាននាក់ចឹង?

ខៈ មាន៤ ប្រុស២តែស្លាប់ទាំងអស់

កៈ អ ហេតុអ្វីបានជាគាត់ស្លាប់មីង?

ខៈ គ្រោះថ្នាក់ចរាចរណ៍

កៈ អ

ខៈ គ្រោះថ្នាក់ភ្លែតៗ អត់មានឈឺអីទេ

កៈ ទាំង២នាក់ហាមីង?

ខៈ អាមួយនេះឈឺតែ៤ថ្ងៃស្លាប់

កៈ អ

ខៈ អាមួយនេះប្រហែល២ឆ្នាំមុននេះឯងគ្រោះថ្នាក់តែមួយភ្លែតទេ

កៈ គ្រោះថ្នាក់នៅណាដែរមីង?

ខៈ នៅស្រុកខ្ញុំនៅពេទ្យសៀមរាបនេះ

កៈ ចាសគាត់អាយុប៉ុន្មានដែរមីងកាលដែលគាត់ស្លាប់

ខ៖ កាលដែលស្លាប់អាយុ៨ឆ្នាំ

ក៖ អគាត់នៅក្មេងហារ

ខ៖ បើសិននៅរស់ចូល១០-១២ ហើយ

ក៖ ចឹងមីងនៅសល់តែកូន២នាក់ទេ

ខ៖ នៅសល់តែ២

ក៖ ហើយកូនអ្នកមីងដែលគាត់អាយុ៦ឆ្នាំ ហ្នឹងគាត់មានឈ្មោះអីដែលមីង?

ខ៖ ឈ្មោះស្រី ស

ក៖ ស្រី ស ហិហិហិ

ខ៖ ឈ្មោះ ស គេហៅចឹងឯង

ក៖ ចាស ប្រហែលជាគាត់សហើយ ចាសហើយកូនៗរបស់អ្នកមីង សម្រាប់កូនពៅហារគាត់រៀនថ្នាក់ទីប៉ុន្មានដែរមីង? ឥឡូវគាត់រៀននៅ?

ខ៖ អត់ទាន់បានរៀនផង

ក៖ អត់ទាន់បានរៀនទេ ចាសចឹងប្រហែលអ្នកមីងអាចអោយក្ដីបំណងរបស់អ្នកមីងអោយគាត់បាន

ខ៖ ហ្នឹងឯង

ក៖ ដោយសារធំឡើងគាត់អាចធ្វើគ្រូធ្វើអីជំនួសអ្នកមីងវិញចឹងហារ អឺសម្រាប់អ្នកមីងៗចេះសាងសង់ផ្ទះសាងសង់អីដែលទេអ្នកមីង?

ខ៖ អ អត់ដែលបានធ្វើទេអត់ចេះសោះ

ខ៖ ស្វាមីអ្នកមីងជាអ្នកធ្វើ អូខេ ចឹងគិតថាជំនាញធ្វើកន្ទេលឬក៏ជំនាញផ្សេងៗដែរអ្នកមីងចេះគិតថាអ្នកមីងហ្នឹងបង្រៀនកូនៗមីងដែលទេ?

ខ៖ ចង់បង្រៀនដែរតែសម័យនេះហើយ

ក៖ ហិហិហិ សម័យទំនើប

ខ៖ វារកដើមចេកកាប់អត់មានទៀតណា

ក៖ ចាស អស់ហើយ

ខ៖ បើនៅស្រុកស្រែសំបូរ នៅនេះអត់មាន

ក៖ ចាស ចុះអ្នកមីងពេលវេលាណាដែលអ្នកមីងលំបាកខ្លាំងហើយអ្នកមីងចងចាំវាអត់ដែលភ្លេចសោះ អ្នកមីងចាំបានដែរទេ ពេលវេលាមួយណាដែរ?

ខ៖ ពេលលំបាកខ្លាំង លំបាកឯណា?

ក៖ ចង់និយាយថាទុក្ខលំបាកមួយដែលអ្នកមីងជួបប្រទះដែលអ្នកមីងចងចាំវារហូតដល់សព្វថ្ងៃដូចជារឿងលំបាកដែលមីងបានវជួបវាមានដែលទេអ្នកមីងមានដែរទេ?

ខ៖ ចង់ថាចាំរហូតដល់សព្វថ្ងៃ រឿងប្តីប្រពន្ធអីហ្នឹងហារ?

ក៖ ចាស រឿងអ្វីក៏ដោយដែលអ្នកមីងជួប ហិហិហិ

ខ៖ អ ជួបបើថាខឹងរឿងប្តីវិញ ខឹងចងចាំអត់ចង់ជួបមុខទៀតទេ តែលែងហើយអត់ចង់ជួបមុខទេដែលធ្វើបាបគេចឹង

ក៖ ចាស

ខ៖ ចងចាំតែរហូតហ្នឹង

ក៖ ហ្នឹងជារឿងដែលមីងចងចាំអត់ដែលភ្លេច?

ខ៖ ចងចាំអត់ដែលភ្លេចទេ នឹកឃើញក៏ខឹងក្តៅរហូត

ក៖ អូចាសមីងកាចហេមីង ចាសចឹងសម្រាប់ដូចជាអាហ្នឹងសម្រាប់ទុកលំបាករបស់មីងដែលមីងចាំអត់ដែលភ្លេចចុះសម្រាប់ពេលសប្បាយរបស់មីង?

ខ៖ ពេលសប្បាយ

ក៖ ចាស ពេលសប្បាយអ្វីដែល?

ខ៖ ពេលសប្បាយៗតែមួយភ្លេតៗសប្បាយកាត់ចោលទៅ

ក៖ ចាស សប្បាយជួបជាមួយគ្រួសារ ចាស អូខេ អ្នកមីងខ្ញុំចង់សួរមួយតើកំលាំងចិត្តអ្វីដែលអោយអ្នកមីងចិញ្ចឹមកូនរហូតដល់សព្វថ្ងៃ

ខ៖ កំលាំងចិត្តហារ?

ក៖ ចាស

ខ៖ កំលាំងចិត្តដោយសារយើងខំចេះតែតស៊ូទៅណាដើម្បីចិញ្ចឹមកូន

ក៖ ចាស តស៊ូដើម្បីពួកគាត់

ខ៖ ហ្នឹងឯង ចេះតែតស៊ូទៅ

ក៖ អឺសម្រាប់អ្នកមីង អឺចឹងមួយនេះគឺជាបទពិសោធន៍ល្អដែលខ្ញុំបានស្ដាប់កន្លងមករបស់អ្នកមីង ចាស ចឹងសម្រាប់ជាចុងក្រោយវិញតើអ្នកមីងមានអ្វីសម្រាប់ផ្ដែផ្ដាំកូនៗរបស់អ្នកមីង ជាសារខ្លីៗសម្រាប់ពួកគាត់ដើម្បីពួកគាត់អាចអនុវត្តន៍តាមអ្នកមីង តាមរយៈបទពិសោធន៍ដែលអ្នកមីងបានរៀបរាប់មកចឹងហារ

ខ៖ ចង់ផ្ដែផ្ដាំកូនថានែកនៅក្មេងចេះចង់ផ្ដាំវាដែលថារៀនដាំរៀនស្លរៀនអីអោយចេះទៅណា

ក៖ ចាសៗ

ខ៖ ក្រែងបានប្ដីទៅកុំអោយធ្វើបាប

ក៖ ចាស

ខ៖ សុំចេះនែក ថាកុំអោយដូចម៉ែ ម៉ែចេះតែទ្រាំទៅណាដាំបាយ បោកអាវ នៅតែគេធ្វើបាបទម្រាំល្ងង់ដូចកូនឯង ចង់បានកូនចឹង ប្រាប់វាតែចុះឯង

ក៖ ចឹងមានតែប៉ុណ្ណឹងទេមីងហារ មានអីផ្ដែផ្ដាំទៀត

ខ៖ មានតែផ្តែផ្កាំចឹងឯងផ្កាំកូនហ្នឹងឯង

ក៖ អូខេ ចឹងខ្ញុំក៏អត់មានអ្វីសួរទៀតដែរ ប៉ុន្តែខ្ញុំអរគុណដែលសម្រាប់ការផ្តល់បទសំភាសន៍ថ្ងៃនេះ

ខ៖ ចាស

ក៖ ចឹងអឺសំនួរចុងក្រោយដែលខ្ញុំចង់សួរជាសំនួរបញ្ចប់សម្រាប់ការសំភាសន៍របស់យើង ចឹងតើអ្នកមីងអនុញ្ញាតអោយខ្ញុំធ្វើការដាក់រូបថតនិងបទសំភាសន៍នេះទៅលើគេហទំព័ររបស់សកលវិទ្យាព្រីហាំមយ៉ុងរបស់យើងបានដែលទេអ្នកមីង?

ខ៖ ហារ?

ក៖ អ្នកមីងអនុញ្ញាតអោយខ្ញុំធ្វើការដាក់រូបថតមីងនិងបទសំភាសន៍មីងក្នុង Website ព្រីហាំមយ៉ាំងយើងបានដែលទេអ្នកមីង?

ខ៖ អឺថាម៉េចម្តងទៀតមើល

ក៖ អឺខ្ញុំចង់សួរថាតើអ្នកមីងអនុញ្ញាតអោយខ្ញុំធ្វើការដាក់រូបថតអ្នកមីងហើយហ្នឹងបទសំភាសន៍ដែលខ្ញុំកំពុងសំភាសន៍អ្នកមីងហ្នឹងទៅក្នុងគេហទំព័រសកលវិទ្យាល័យព្រីហាំមយ៉ាំងរបស់យើងបានដែលទេអ្នកមីង?

ខ៖ ដាក់ទៅមានអីទេ

ក៖ ចាសៗចឹងថ្ងៃនេះខ្ញុំអរគុណច្រើន

ខ៖ ចាស

ក៖ ចាសចឹងអ្នកមីងការសំភាសន៍របស់យើងថ្ងៃហ្នឹងគឺត្រូវបានបញ្ចប់

ខ៖ ចាសៗ៕